**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# ផ្ញើជូន

## លោកស្រី **គីមហ៊ុន ម៉ាក់ធូរី** ព្រមទាំងក្រុមគ្រួសារ

*លោកស្រីជាទីរាប់អាន,*

ភរិយាខ្ញុំ និងរូបខ្ញុំបានទទួលដំណឹងដ៏ក្រៀមក្រំ ក្តុកក្តួល និងសោកស្តាយរកអ្វីមកប្រៀបផ្ទឹមពុំបាន ដោយទទួលដំណឹងថា ឯកឧត្តម **សៀង គីមហ៊ុន** ទីប្រឹក្សាផ្ទាល់របស់ខ្ញុំ និងត្រូវជាឪពុកបង្កើតរបស់លោកស្រីបានទទួលមរណភាពក្នុងជន្មាយុ ៨៥ ឆ្នាំ ដោយជរាពាធ ។

មរណភាពរបស់ឯកឧត្តម គឺជាការបាត់បង់បិតា ជីតាជាទីគោរពស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ និងជាការបាត់បង់នូវសហការីរបស់ខ្ញុំមួយរូប ដែលធ្លាប់បានរួមសុខរួមទុក្ខជាមួយគ្នាក្នុងការបំរើជាតិ និងប្រជាជនកម្ពុជាកន្លងមក រហូតដល់ថ្ងៃអវសាននៃជីវិត ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ភរិយាខ្ញុំ និងរូបខ្ញុំ សូមចូលរួមចែករំលែកនូវមរណទុក្ខដោយក្តីស្រណោះ និងការអាឡោះអាល័យជាមួយលោកស្រី និងបុត្រា បុត្រី ព្រមទាំងបងប្អូនកូនក្មួយទាំងអស់នៃសព ដោយសេចក្តីសង្វេគជាទីបំផុត ។

ភរិយាខ្ញុំ និងរូបខ្ញុំ សូមឧទ្ទិសបួងសួងអោយដួងវិញ្ញាណក្ខន្ធឯកឧត្តម **សៀង គីមហ៊ុន** បានចាប់កំណើតក្នុងសុគតិភពគ្រប់ៗជាតិកុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកស្រី ព្រមទាំងក្រុមគ្រួសារទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ៕

*ថ្ងៃ សៅរ៍ ២កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩*

**ហ៊ុន សែន**